# RUPES:

# យុទ្ធសាស្ត្រក្នុងការផ្តួចផ្តើមដើម្បីផ្តល់ការតបស្នងដល់អ្នកក្រីក្រ តំបន់ខ្ពស់នៅអាស៊ីក្នុងការពារ និងធ្វើឱ្យប្រសើរឡើង នូវបរិស្ថានរបស់យើង

## An innovative strategy to reward Asia's upland poor for preserving and improving our environment

Edited by:
Grace Villamor and Beria Leimona

2010

**Disclaimer and copyright :**

ICRAF holds the copyright to its publications and web pages but encourages duplication, without alteration, of these materials for non-commercial purposes. Proper citation is required in all instances. Information owned by other providers and requiring permission is marked as such. Website links provided by our site will have their own policies that must be honoured. The information provided by ICRAF is, to the best of our knowledge, accurate although we do not warranty the information nor are we liable for any damages arising from use of the information. ICRAF maintains a database of users although this information is not distributed and is used only to measure the usefulness of our information. Without restriction, please add a link to our website www.worldagroforestrycentre.org/sea on your website or publication.

**Acknowledgment :**

The Program for Developing Mechanisms for Rewarding the Upland Poor in Asia for Environmental Services they provide (RUPES) is financially supported by the International Fund for Agricultural Development (IFAD).

**Correct citation:**

Villamor G and Leimona B. 2010. An innovative strategy to reward Asia's upland poor for preserving and improving our environment. Bogor, Indonesia. World Agroforestry Centre.

Published by
World Agroforestry Centre
ICRAF Southeast Asia Regional Office
Jl. CIFOR, Situ Gede, Sindang Barang, Bogor 16115
PO Box 161, Bogor 16001, Indonesia
Tel: 62 251 8625415, fax: 62 251 8625416
Email: icraf-indonesia@cgiar.org
Website: http://www.worldagroforestry.org/sea

2010

**Edited:**
Grace B. Villamor and Leimona Beria

**Translated:**
Seng Sary

**Design & layout:**
Josef Arinto

**Cover Design:**
Tikah Atikah

**Cover Photos:**
Grace B. Villamor & ICRAF

## Table of contents

០១
RUPES: យុទ្ធសាស្ត្រក្នុងការផ្តួចផ្តើមដើម្បីផ្តល់ការតបស្នងដល់អ្នកក្រីក្រតំបន់ខ្ពស់នៅអាស៊ីក្នុងការពារ និងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានរបស់យើង

០៥
សេវាកម្មបរិស្ថានដែលសហគមន៍តំបន់ខ្ពស់អាចនឹងទទួលបានរង្វាន់រួមមាន:

០៩
RUPES: ប្រវត្តិ សកម្មភាព និងអភិវឌ្ឍន៍

១៣
កម្ពុជា-របកគំហើញថ្មីនៃការផ្តល់ការតបស្នងក្នុងកម្មវិធីសេវាកម្មបរិស្ថានសំរាប់អ្នកក្រីក្រ

15
RUPES: An innovative strategy to reward Asia's upland poor for preserving and improving our environment:

17
Environmental Services:

21
RUPES: Background, activities, and developments:

25
Cambodia: Exploring new ES reward schemes for the poor

# RUPES:
# យុទ្ធសាស្រ្តក្នុងការផ្តួចផ្តើមដើម្បីផ្តល់ការតបស្នងដល់អ្នកក្រីក្រតំបន់ខ្ពស់នៅអាស៊ីក្នុងការពារ និងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានរបស់យើង

អ្នកក្រីក្រនៅតំបន់ខ្ពស់ គឺជាអ្នកការពារបរិស្ថានដែលត្រូវបានគេបំភ្លេចចោលនៅតំបន់ខ្ពង់រាប និងតំបន់ភ្នំដែលគ្របដណ្តប់ ជិតពាក់កណ្តាលតំបន់អាស៊ី ។

លោកបណ្ឌិត **ឌិនីស ហ្គារីធី** Dr. Dennis Garrity អ្នកគ្រប់គ្រងទូទៅនៃមជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក (អ៊ីក្រាស-ICRAF) ដែលមានទីតាំងនៅ ណៃរ៉ូប៊ី Nairobi បានមានប្រសាសន៍ថា: "អ្នកក្រីក្រតំបន់ខ្ពស់នៅអាស៊ីភាគច្រើនជាជនជាតិភាគតិចដែលគ្រប់គ្រងតំបន់ព្រៃឈើ និងផ្តល់សេវាកម្មបរិស្ថានដូចជា ទឹកស្អាត និងការអភិរក្សជីវៈចំរុះដែលផ្តល់ប្រយោជន៍ដល់មនុស្សទូទៅ" ។

ប៉ុន្តែអ្នកក្រីក្ររស់នៅតំបន់ខ្ពស់មិនសូវបានទទួលការតបស្នង រឺ ទទួលស្គាល់នូវការប្រឹងប្រែងរបស់ពួកគេក្នុងការការពារបរិស្ថានដែលកំពុងទទួលរងការបាត់បង់នោះឡើយ" ។

(អ៊ីក្រាស-ICRAF) និងដៃគូការងារដ៏ទៃទៀតសង្ឃឹមថានឹងអាចផ្លាស់ប្តូរ តាមរយៈកម្មវិធីផ្តួចផ្តើមគំនិតដែលហៅថា RUPES ដែលមានន័យថា: ការផ្តល់ការតបស្នងនូវអត្ថប្រយោជន៍ និងការចូលរួមវិនិយោគក្នុងកម្មវិធី ផ្តល់ការគាំទ្រចំពោះអ្នកក្រីក្រក្នុងសេវាកម្មបរិស្ថាន. RUPES បានបង្កើតឡើងតាមរយៈ ការផ្តល់ជំនួយជាដៃគូរជាមួយនិងមូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៏វិស័យកសិកម្ម (IFAD) និងសម្របសម្រួលដោយ កម្មវិធី ICRAF ប្រចាំតំបន់អាស៊ីអាគ្នេយ៍ ដែលមានការិយាល័យនៅ បូ'ត័រ ប្រទេសឥណ្ឌូនេស៊ី ។

លោកបណ្ឌិត **ឌិនីស** ហ្គារីធី បានពន្យល់ថា "អ្នកក្រីក្រនៅជនបទរកចំណូលបានដោយសារការប្រមូលអនុផលពីធនធាន ធម្មជាតិដូចជា ការកាប់ឈើលក់ និងការកាប់ព្រៃឈើដើម្បីបានដីធ្វើកសិកម្ម ។ ប៉ុន្តែអ្វីដែលគួរឱ្យហួលចិត្ត គឺការការពារធនធានបរិស្ថានរបស់ពួកគេទាំងនោះមិនទទួលបានចំណូលអ្វីបន្តិចសោះ" ។

ទោះបីយ៉ាងណាក៏ដោយ យ៉ាងហោចណាស់ RUPES កំពុងធ្វើការយ៉ាងសកម្មជាមួយនិងដៃគូរទៅលើ ថាតើគួរផ្តល់រង្វាន់យ៉ាងដូចម្តេចចំពោះតួនាទីរបស់ពួកគេដែលជាអ្នកគ្រប់គ្រងនៅតំបន់ខ្ពស់ ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងខណៈដែលពួកគេកំពុងតែគាំទ្រក្នុងការការពារបរិស្ថានជាសាកល ក៏ដូចជានៅតំបន់ខ្ពស់នៅអាស៊ី"

## សេវាកម្មបរិស្ថាន

អ្នកក្រីក្រនៅតំបន់ខ្ពស់មានចំនួន ១ភាគ៤ នៃអ្នកក្រីក្រ[1] សរុបនៅអាស៊ី ដែលពួកគេមានលំនៅស្ថាននៅតំបន់ខ្ពង់រាបដែល ជាតំបន់ព្រៃឈើដុះ និងតំបន់កសិកម្មនៅច្របូកច្របល់គ្នា ហើយតំបន់ខ្លះជាតំបន់ព្រៃឈើចុងក្រោយគេរបស់ពិភពលោក ។ ប្រព័ន្ធអេកូឡូស៊ីទាំងនោះបានធ្វើឱ្យមានកំដៅផែនដីកើនឡើងយឺតៗដោយស្រូបយកសារធាតុកាបូនចេញពីកាបូនឌីអុក ស៊ីត និងឧស្ម័នផ្ទះកញ្ចក់ដែលរថយន្តនិងរោងចក្រឧស្សាហកម្មបញ្ចេញទៅក្នុងបរិយាកាស ។

[1] ប្រហែល ២៥០ លាននាក់

លោកបណ្ឌិត ជិនទីស ហ្គារីធី មានប្រសាសន៍ថា "ប្រព័ន្ធកសិ-រុក្ខកម្មគឺជាឋានសួគ៌នៃជីវៈចំរុះ ។ ដំណាំហូបផ្លែនៅក្នុងតំបន់ព្រៃដែលមានមនុស្សភាគច្រើនមិនទាន់យកចិត្តទុកដាក់បានផ្តល់ឱ្យយើង និងកូនចៅរបស់យើងនូវឱសថអាហារ និង ផលិត ផលឧស្សាហកម្ម" ។

ទីជម្រាលនៅតំបន់ខ្ពស់ដែលស្អាត គឺជាតម្រងនៃទឹកភ្លៀងដែលផ្តល់នូវទឹកស្អាតសំរាប់បរិភោគ អនាម័យ ធារាសាស្ត្រ និង ថាមពល ។ វាក៏ការពារសំណឹក ការបាក់ដី និងទឹកជំនន់នៅតំបន់ទំនាបផងដែរ ។ ហើយសោភ័ណនៃព្រៃឈើផ្តល់នូវអត្ថ ប្រយោជន៍ផ្នែកទេសចរណ៍ធម្មជាតិសំរាប់អ្នកអេកូឡូស៊ី និងអ្នកទេសចរណ៍ ហើយក៏ជាប្រភពនៃឱកាសសេដ្ឋកិច្ចរបស់ សហគមន៍ក្រីក្រ ។

ប៉ុន្តែប្រព័ន្ធអេកូឡូស៊ីនៅតំបន់ខ្ពស់ ដែលធ្វើឱ្យជីវិតយើងប្រសើរឡើងគ្រប់គ្នានោះ កំពុងតែរងការខូចខាតយ៉ាងខ្លាំង ។ ព្រៃឈើកំពុងតែដួលរលំដោយសាររណារយន្ត ។ ការអភិវឌ្ឍន៍លំនៅដ្ឋាន ការស្ថាបនាផ្លូវថ្នល់ ការកាប់គាស់ដីថ្មីដើម្បីកសិកម្ម កំពុងតែផ្លាស់ប្តូរជាប្រចាំនូវប្រព័ន្ធអេកូឡូស៊ីនៅតំបន់ខ្ពស់ ។ "ព្រៃកៅស៊ូ" កសិ-រុក្ខកម្ម អាងទឹកសំរាប់ដំណាំ ដែលផ្តល់កៅស៊ូយ៉ាងច្រើនកំពុងតែជាមធ្យោបាយបង្កើតនូវវប្បធម៌តែមួយនៃការដំណាំកៅស៊ូ និងដូងប្រេង ។ កំណើនប្រជាជន និងការគៀបសង្កត់ផ្នែកសេដ្ឋកិច្ចបានជំរុញឱ្យកសិករទទួលយកនូវការធ្វើកសិកម្មដោយមិនមាននិរន្តរភាពផ្នែកបរិស្ថាន ដូចជា ការដុតព្រៃដើម្បីធ្វើកសិកម្មនៅតំបន់ជម្រាលជាមួយនិងការទុកពេលមិនគ្រប់គ្រាន់ក្នុងការធ្វើឱ្យដីមានសុខភាពឡើងវិញ ។ ជាលទ្ធផល គឺបានលេចចេញនូវ សំណឹក ការបាក់ដី និងទឹកជំនន់ ។

IFAD រកឃើញថា កសិករនៅតំបន់ខ្ពស់ជាពិសេសនៅអាស៊ីបានចូលរួមចំណែកដោយមិនស្មើភាពនៅផ្នែកអវិជ្ជមាននៃ ការអភិវឌ្ឍន៍ ។ ពួកគេភាគច្រើនជាជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ដោយសារពួកគេខ្វះសិទ្ធិស្របច្បាប់ដើម្បី ធ្វើកសិកម្ម រឺសូម្បីតែសិទ្ធិក្នុងការថែរក្សាដីនោះ ហើយកាន់តែគ្មានសិទ្ធិក្នុងការផ្ទេរដីនោះទៅឱ្យកូនចៅរបស់ពួកគេ ។

អ្នកក្រីក្រនៅតំបន់ខ្ពស់មិនសូវមានជំរើស ក្នុងការធ្វើឱ្យមានការខូចខាតផ្នែកបរិស្ថាន ភាគច្រើនពួកគេគ្មានសិទ្ធិទៅលើដី នោះពួកគេមានការលើកទឹកចិត្តតិចតួចក្នុងការការពារដីនោះ ។ អ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រទាំងនោះ ឆ្លងកាត់នូវ ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងជម្រើសតិចតួចផ្នែកជីវភាព ពួកគេបានចូលរួមចំណែកក្នុងការបំផ្លាញ រឺនៅស្ងៀម និងឈរ មើលការបំផ្លាញធនធានធម្មជាតិទាំងនោះដែលកំពុងតែរចិញ្ចឹម និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ។







## យុទ្ធសាស្ត្ររបស់ RUPES

សេវាកម្មបរិស្ថានដែលសហគមន៍តំបន់ខ្ពស់អាចនឹងទទួលបានរង្វាន់រួមមានៈ

– ការកាត់បន្ថយសារធាតុកាបូន
– ការការពារតំបន់ជម្រៀល
– ការការពារជីវៈចំរុះ
– ការធ្វើឱ្យមានសោភ័ណភាពទេសភាព

បេះដូងនៃយុទ្ធសាស្ត្ររបស់ RUPES គឺធ្វើការសាកល្បងនូវវិធីសាស្ត្រគ្រប់កំរិត ដែលធ្វើឱ្យសេវាកម្មបរិស្ថានអាចមានប្រយោជន៍សំរាប់សហគមន៍នៅតំបន់ខ្ពស់ដែលជាអ្នកការពារបរិស្ថាន ។ ហើយក៏ជាកម្មវិធីដែលសាកល្បងនូវវិធីសាស្ត្រ និងការផ្តួចផ្តើមមានលក្ខណៈជាស្ថាប័នដែលសហគមន៍នៅតំបន់ខ្ពស់ត្រូវការ បង្កើននូវជំរើសក្នុងការរស់នៅរបស់ពួកគេ ដោយផ្តល់នូវការទទួលស្គាល់ និងសេវាកម្មដ៏មានតំលៃទៅអ្នកដទៃផ្សេងទៀត ។

ដើម្បីធ្វើឱ្យងាយស្រួល សហគមន៍ត្រូវតែរៀនអំពីការត្រួតពិនិត្យ និងវាស់វែងសេវាកម្មបរិស្ថានដែលពួកគេកំពុងតែផ្តល់ ដូច្នេះពួកគេអាចមានចំណេះដឹងប្រសើរឡើង ហើយអាចត្រួតពិនិត្យបានក្នុងករណីនៃការលក់សេវាកម្មទាំងនេះទៅឱ្យអ្នកទិញដែលមានសក្តានុពលណាម្នាក់ ។

រង្វាន់សម្រាប់សហគមន៍នៅតំបន់ខ្ពស់រួមមាន ការអភិវឌ្ឍន៍កម្ចីឥណទាន ហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារដែលផ្តល់នូវការបង្កើន អនុផល និងផលានុផល ពង្រីកសេវាកម្មក្នុងការធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេសកសិ-រុក្ខកម្ម និងការចំណាយជាសាច់ប្រាក់សុទ្ធ ។ “ជួយសហគមន៍អ្នកនៅតំបន់ខ្ពស់កំណត់នូវផលតបស្នង រឺយន្តការក្នុងការធ្វើការការងារឱ្យប្រសើរ គឺជាអទិភាពចំបងរបស់ RUPES” ។

សិទ្ធិកាន់កាប់ដីធ្លី អាចជាយន្តការជំរុញ រឺ ការវិនាសអន្តរាយមួយសំរាប់ផ្តល់នូវសេវាកម្មបរិស្ថាន ។

# ការកាត់បន្ថយសារធាតុកាបូន

ឧស្ម័នផ្ទះកញ្ចក់(GHG) នៅក្នុងបរិយាកាសដូចជា កាបូនឌីអុកស៊ីត មេតាន និងនីត្រូសអុកស៊ីតបង្ករឱ្យពន្លឺថ្ងៃចូលទៅក្នុងបរិយាកាសដោយសេរីនៅពេលដែលពន្លឺនោះប៉ះផែនដី កំដៅខ្លះត្រូវបានចាំងត្រឡប់ទៅក្នុងលំហរវិញ ។ ប៉ុន្តែផ្ទះកញ្ចក់បានទប់កំដៅនោះនៅក្នុងបរិយាកាស ។

អ្នកវិទ្យាសាស្ត្រផ្នែកបរិស្ថានភាគច្រើនយល់ឃើញដូចគ្នាថា ការកើនឡើងនូវកំរិតឧស្ម័នផ្ទះកញ្ចក់ជាមូលហេតុនៃការកើន ឡើងកំដៅផែនដីដែលអាចបង្កើនកំដៅផែនដីយ៉ាងឆាប់ពី ១ ទៅ ៥ អង្សារសែលស៊ីស (degree celsius) ។ នេះអាចជាគន្លឹះនៃការលាយផែនទឹកកកដែលផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីនៅតំបន់ព្រៃហេមពាន្ត (Himalaya), អាន់ដេស (The Andes), និងតំបន់ទំនាប ។ ការរលាយទឹកកកអាចធ្វើឱ្យនីវ៉ូទឹកសមុទ្រកើនឡើង ហើយជន់លិចតំបន់មាត់សមុទ្រ ដូចជា ប្រទេសបង់ក្លាដេស តំបន់ដីសណ្តរទន្លេមេគង្គ និងតំបន់ភាគច្រើននៃរដ្ឋហ្វ្លរីដា និងលូស៊ីអាណា សហរដ្ឋអាមេរិក ។ កោះជា ច្រើននៅមហាសមុទ្រប៉ាស៊ីហ្វិកអាចបាត់ចេញពីផែនទីពិភពលោក ។ ផលប៉ះពាល់ផ្សេងទៀតដែលកើតចេញពីបំរែបំរួល បរិយាកាសគឺជាការបំរែបំរួលបរិយាកាសធ្វើឱ្យសំណើកនៅតំបន់មាត់សមុទ្រ បង្កើននូវជាតិអំបិល និងបាត់បង់នូវផ្កាថ្មបំប្រះ ទឹក ។

ប្រជាជនក្រីក្រតឹរងគ្រោះជាងគេ ពីព្រោះពួកគេរស់នៅដោយពឹងលើអាកាសធាតុ ហើយពួកគេផ្តោតការយកចិត្តទុកដាក់ នៅតំបន់ត្រូពិចជាកន្លែងដែលកំដៅផែនដីប៉ះពាល់ខ្លាំងជាងគេ ។

ចំហេះនៃប្រេងឥន្ធនៈដូចជា សាំង ប្រេងម៉ាសូត និងផ្សេងចេញពីរោងចក្រឧស្សាហកម្ម និងគមនាគមន៍ បានផលិតប្រមាណ ៦៥% នៃឧស្ម័នផ្ទះកញ្ចក់ ។ ទូទាំងពិភពលោក ភ្លើងឆេះព្រៃ និងការដុតព្រៃតាមបែបកសិកម្មពនាចរបាន ផលិតឧស្ម័នផ្ទះ កញ្ចក់ប្រហែល ២០% ។

ការបញ្ចេញសារធាតុកាបូននៅកុងពិភពលោក គឺ ១.១ តោន ក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំ ។ វាពិតជាច្រើនខ្លាំងណាស់ ប៉ុន្តែការបញ្ចេញសារធាតុកាបូននៅប្រទេសកំពុងអភិវឌ្ឍន៍គឺ ៣.១ តោនក្នុង ១ ហិកតា ហើយ ៥.៦ តោននៅសហរដ្ឋអាមេរិក ។

ពិធីសារនៅទីក្រុងតូក្យូដែលបានចុះហត្ថលេខា ដោយប្រទេសចំនួន ១៨០ នៅឆ្នាំ ១៩៩៧ ដោយមានការខិតខំប្រឹងប្រែងដោយប្រទេសឧស្សាហកម្មចំនួន ៣៨ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅត្រឹមឆ្នាំ ២០១២ ចំនួន ៥.២% តិច ជាងឆ្នាំ ១៩៩០[២] ។

ដើមឈើបង្អាក់ និងស្លឹកវី ស្រូបយកសារធាតុកាបូនចេញពីបរិយាកាស ដូច្នេះដើមឈើអាចជួយកាត់បន្ថយការឡើងកំដៅ ផែនដី ។ ការបំបែក និងការដុតរុបធាតុដែលគ្មានជាតិគីមីបានបញ្ចេញសារធាតុកាបូនចូលទៅក្នុងបរិយាកាស ។

ប្រព័ន្ធអេកូឡូស៊ីខុសពី "Carbon Sink". នៅក្នុងព្រៃពញវិយការបំបែករូបអាចទូទាត់និងការកាត់បន្ថយសារធាតុកាបូនបាន ។ ដោយឡែក ព្រៃក្មេងមានប្រសិទ្ធខ្ពស់នៃសំណោញ់ស្រូបសារធាតុកាបូន.

[២] ពិធីសារនៅទីក្រុងតូក្យូមិនមាន់បានធ្វើសច្ចាប័នពីគ្រប់ប្រទេសឱ្យមានកំលាំងគ្រប់គ្រាន់នៅឡើយទេ

**លោក មីនណេ វ៉ានខូតវិក** ជាទីប្រឹក្សាវិទ្យាសាស្ត្រសាកលរបស់ ICRAF បានមានប្រសាសន៍ថា: "១ ហិកតានៃដីមិនបង្ករ បង្កើនផល ដីវាលស្មៅមិនបានស្រូបយកសារធាតុកាបូននោះទេ ប៉ុន្តែបើផ្លាស់ប្តូរដីនោះទៅជាដីកសិ-រុក្ខកម្ម គឺ ដី១ ហិកតា នោះអាចស្រូបយកសារធាតុកាបូនជាង ៣ តោន"។

"Carbon Swapping" យុទ្ធសាស្ត្រមួយដែលតាមរយៈក្រុមហ៊ុនផ្សេងៗនៅបណ្តាប្រទេសឧស្សាហកម្មអាចជួយផ្តល់ មូលនិធិសំរាប់គំរោងដែលធ្វើឱ្យមានការស្រូបយកឧស្ម័នផ្ទះកញ្ចក់ ដូចជាការរក្សា Carbon Sink តាមរយៈព្រៃឈើ ដែល ជាការដោះដូរនូវការបញ្ចេញសារធាតុកាបូនរបស់ពួកគេ។

## ការការពារតំបន់ទីជម្រៀល

យើងបានចំណាយថវិការយ៉ាងធំធេងក្នុងការទប់ស្កាត់ការខូចខាតតំបន់ទីជម្រៀលនៅតាមតំបន់ខ្ពស់នៅអាស៊ី។ បច្ចុប្បន្ន ១ ភាគ ៥ នៃប្រជាជននៅលើផែនដីខ្វះទឹកស្អាតបរិភោគ និងពាក់កណ្តាលគ្មានអនាម័យ។

ជារៀងរាល់ឆ្នាំ ទឹកជំនន់បានសម្លាប់មនុស្សរាប់ពាន់នាក់ ហើយរាប់រយពាន់នាក់ទៀតបាត់បង់ផ្ទះសម្បែង។ ទ្រព្យសម្បត្តិ ដែលខូចខាតមានតំលៃរាប់ពាន់លានដុល្លា។ ល្បាប់ភក់នៃទំនប់វារីអគ្គីសនីផលិតអគ្គីសនីគួរឱ្យទុកចិត្តបានបន្តិចបន្តួច ហើយ មានតម្លៃកាន់តែថ្លៃឡើង។ គ្រឿងបំពុលរាងកាយបានគំរាមកំហែង ត្រី សត្វ និងរុក្ខជាតិ *delicate aquatic ecosystem* និងគុណភាពទឹកដែលយើងបរិភោគ និងប្រើប្រាស់។

លោក មីនណេ វ៉ាន ខូតវិក បាននិយាយថា "ព្រៃឈើមានមុខងារ ៣ ធំៗក្នុងការថែរក្សាសុខមាលភាពនៃតំបន់ទី ជម្រៀល"

ទី ១ ដីព្រៃមានមានគីរិតជ្រៀបទឹកខ្ពស់ ដូច្នេះព្រៃឈើអាចជួយការហូរទឹកទៅក្នុងទន្លេ ស្ទឹង រឺជ្រោះ។ ព្រៃឈើក៏ជួយ ពន្យឺតការហូរដោយរក្សាទឹកជាបណ្តោះអាសន្ននៅតាមផ្លូវដែលទឹកកំពុងហូរចូលទៅស្ទឹង រឺទន្លេ។

លោក មីនណេ វ៉ាន ខូតវិក បញ្ជាក់ថា "ប៉ុន្តែយើងមិនត្រូវការព្រៃឈើគ្រប់ដណ្តប់គ្រប់ទីសទីដើម្បីទទួលគុណប្រយោជន៍ ពីមុខងាររបស់ព្រៃឈើនោះឡើយ កសិករអាចដាំដើមឈើជាមួយ និងធុញ្ញជាតិនោះពិភពលោកនិងទទួលបានអត្ថ ប្រយោជន៍ដូចៗគ្នា"



ប្រាកដណាស់ អ្នកថែរក្សាតំបន់ទីជម្រៀលដែលបានការពារសំណឹក និងទឹកជំនន់ ហើយដែលផ្តល់ឱ្យយើងនូវទឹកស្អាត សំរាប់បរិភោគ មានអនាម័យ ប្រព័ន្ធធារាសាស្ត្រ ហើយនិងថាមពល គួរតែត្រូវបានអត្ថប្រយោជន៍តបស្នង។

សហគមន៍នៅតំបន់ខ្ពស់អាចធ្វើទីផ្សារ នៃការការពារតំបន់ជម្រៀលតាមរយៈសេវាកម្មដូចជា ការធ្វើឱ្យការគ្រប់គ្រង និង ការការពាព្រៃឈើឱ្យកាន់តែប្រសើរឡើង ហើយនឹងការដាំព្រៃឈើឡើងវិញ។

ផលិតផលសំរាប់ធ្វើទីផ្សារនៃការការពារតំបន់ជម្រៀលរួមមាន:

- លោទានគុណភាពទឹក : អត្ថប្រយោជន៍នៃការកាត់បន្ថយ sediment សារធាតុគីមី និង nutrients នៅក្នុងទឹក អាចចំណាយសំរាប់អ្នកដែលកាន់កាប់តំបន់ខ្ពស់ ជាមួយនឹងលោទានគុណភាពទឹក តាមរយៈការធ្វើឱ្យប្រសើរឡើង នៅតំបន់ ជម្រៀល និងជីវភាពប្រជាជន នៅតំបន់ខ្ពស់ខ្លួនឯងផ្ទាល់។

- ការចុះកិច្ចសន្យាលើការការពារតំបន់ជម្រៀល :ការកំណត់ការចំណាយ អាចជាការចរចារវាងអ្នកការពារតំបន់ ជម្រៀល និងអ្នកទទួលបានអត្ថប្រយោជន៍ នៅតំបន់ទំនាបដូចជា រោងចក្រវារីអគ្គីសនី ឧស្សាហកម្មចែកចាយទឹក និងប្រព័ន្ធធារាសាស្រ.

- ឈេទានសារជាតិប្រៃ : នៅក្នុងតំបន់ដែលមានសារជាតិអំបិលនៅក្នុងដីគឺមានបញ្ហាយ៉ាងធំ ដូចជាតំបន់ភាគច្រើន នៅប្រទេសអូស្រាលី ការដាំព្រៃឈើនៅតំបន់ទំនាបអាចកាត់បន្ថយសារជាតិអំបិលនៅស្រទាប់ដីតាមរយៈការ រំហួត ។ ការថយចុះនៃសារជាតិអំបិលនៅក្នុងលំហូរទឹកគឺ ទទួលបានអត្ថប្រយោជន៍ទាំងតំបន់ខ្ពស់ និងតំបន់ទំនាប ដែលតំបន់ទាំងនោះត្រូវបានថែរក្សាដោយប្រុងប្រយ័ត្ន ។

## ការអភិរក្សជីវចំរុះ

តាមការសន្និដ្ឋានមួយ សត្វពាហនៈនៅលើផែនដី ២៤ %  និងជំពូកសត្វស្លាប ១២% ប្រឈមមុខនឹងការផុតពូជ នេះបើ យោងតាមអង្គការអាហារ និងកសិកម្ម ។ ការបាត់បង់ទីជំរកគឺជាបុព្វហេតុចំបងនៃការផុតពូជនេះ ។ ការកាប់បំផ្លាញព្រៃឈើ នៅតំបន់ត្រូពិច និងធ្វើឱ្យបាត់បង់ជំពូកជីវចំរុះពី ៥-១៥% នៅលើពិភពលោកក្នុងចន្លោះឆ្នាំ ១៩៩០-២០២០ នេះបើយោង តាមវិទ្យាស្ថានធនធានពិភពលោក ។

សហគមន៍តំបន់ខ្ពស់ដែលក្រីក្រអាចដើរតួជាអ្នកការពារ និងម្ចាស់នៃជីវចំរុះដ៏សំបូរបែបរបស់ដំណាំ សត្វពាហនៈ និងសរីរៈតូចៗនៅក្នុងតំបន់ព្រៃឈើ ប៉ុន្តែសហគមន៍ក្រីក្រមិនសូវមានមធ្យោបាយដើម្បីគាំទ្រ និងការពារជីវចំរុះទាំងនោះទេ ។ RUPES គឺកំពុងតាមដានលើនិន្នាការដែលលេចឡើងសំរាប់ទីផ្សារនៃការការពារជីវចំរុះព្រៃឈើ ។

សំភារៈដែលប្រើសំរាប់ធ្វើទីផ្សារនៃសេវាកម្មការពារជីវៈចំរុះរួមមាន :

- **ការចែករំលែកក្នុងជំនួញជីវចំរុះ** ជំនួញបែបពាណិជ្ជកម្មដែលទទួលបានចំនេញពីជីវៈចំរុះអាចចែករំលែកដើម្បីជំនួយដល់សហគមន៍ក្រីក្រដែលកំពុង តែការពារធនធានព្រៃឈើរបស់ពួកគេ ។

- ***Bioprospecting rights.*** *Purchasers of bioprospecting rights-* ប្រមូល និងធ្វើការសាកល្បងសំភារៈដែលបានមកពីតំបន់ព្រៃដោយរួមមានក្រុមហ៊ុនផលិតឱសថ និងក្រុមហ៊ុនកសិរ-ឧស្សាហកម្ម និងស្ថាប័ន ស្រាវជ្រាវផងដែរ ។

- **ឈ្នាទានជីវៈចំរុះ** នៅពេលដែលការអភិវឌ្ឍន៍ធ្វើឱ្យបាត់បង់ជីវចំរុះ អ្នកធ្វើការអភិវឌ្ឍន៍អាចទាមទារឱ្យមានការ ទូទាត់ការបំផ្លិចបំផ្លាញនេះដោយផ្តល់នៅឥណទានដើម្បីធ្វើឱ្យប្រើសើរឡើងនៅជីវៈចំរុះកន្លែងផ្សេងទៀត ។

- **ផលិតផលជីវៈចំរុះបែបមិត្តភាព** ផលិតផលជីវៈចំរុះបែបមិត្តភាពខ្លះនាំយកមកនូវដំណើរការខ្ពស់ជាងផលិតផល សមញ្ញដទៃទៀត ។ ភាពខុសគ្នានៃតំលៃនេះអាចយកទៅប្រើដើម្បីការពារជីវចំរុះ ។ ឧទាហរណ៍ : Coffees, shade-grown រឺ Bird Friendly ដែលបានធ្វើទីផ្សារដោយស្ថាប័ន Smithsonian គឺរីកលូតលាស់បែបធម្មជាតិ នៅក្រោមដើម Canopy  ។ ការផ្លាស់ប្តូរម្នាក់ម្តងគឺ កសិដ្ឋាន "កាហ្វេព្រះអាទិត្យ" ដែលត្រូវការថ្នាំពុល និងជីគីមីចំនួនច្រើន

# RUPES: ប្រវត្តិ សកម្មភាព និងអភិវឌ្ឍន

ក. ភាពប្រាកដនិយម : ភាពប្រាកដនិយមមួយនៃកម្មវិធីផ្តល់ការតបស្នងគឺបានកាត់បន្ថយ និងបញ្ចៀសការគំរាមកំហែងដល់សេវាកម្មបរិស្ថាន ដែលកើតឡើងនៅពេលដែលអវត្តមាននៃការធ្វើអន្តរាគមន៍ផ្សេងៗ ។ ដើម្បីធ្វើឱ្យវាអាចកើតមានទៅបាន អត្ថប្រយោជន៍របស់អ្នកលក់ និងអ្នក ទិញគួរតែប្រាកដប្រជា និងមានចីរភាព ។

ខ. លក្ខខ័ណ្ឌ : ក្ខខ័ណ្ឌនៃការផ្តល់ការតបស្នងគួរតែអាចភ្ជាប់សេវាកម្មបរិស្ថានដែលមានស្រាប់ជាមួយនឹងការចាប់ផ្តើមផ្តល់នៅការតបស្នងក្នុង តំរិយាបថមួយដែលបញ្ជាក់ពីតម្លាភាពក្នុងការកំណត់ នៅពេលដែលមានការផល់ការតបស្នង រឺក៏មិនផល់ ។

គ.ការស្ម័គ្រចិត : ការផល់ផលតបស្នង គឺធ្វើឡើងដោយស្ម័គ្រចិតនៅពេលដែលអ្នកផ្តល់សេវាកម្មបរិស្ថាន មានជំរើសដោយសេរីជាជាងធ្វើតាមបទ បញ្ញាតិ ។ ទាំងអ្នកលក់ និងអ្នកទិញ គឺយល់ព្រមដោយស្ម័គ្រចិត្ត ដោយមានកិច្ចសន្យា ។ ដូច្នេះវាធ្វើឱ្យមានការកើនឡើងនៅអំណាចនូវការតថ្លៃ រវាងភាគីទាំងសងខាង ។

ឃ. ការគាំទ្រចំពោះអ្នកក្រីក្រ: ការតបស្នងចំពោះអ្នកក្រីក្រ គឺផ្តោតទៅលើគុណភាពនៃផលប៉ះពាល់ចំពោះលើអ្នកអនុវត្តន៍ការងារ ដែលការ បង្កើតនូវកម្មវិធីដើម្បីឱ្យមានភាពលំអៀងជាវិជ្ជមានចំពោះអ្នកណាដែលស្ថិតក្នុងសភាពក្រីក្រ ។

បញ្ញាតិនៃការផ្តល់ការតបស្នងចំពោះមនុស្សដែលការពារ និងធ្វើឱ្យប្រសើរឡើងនូវសេវាកម្មបរិស្ថាន គឺផ្តល់ប្រយោជន៍ ចំពោះការធ្វើពាណិជ្ជកម្ម រឺប្រជាជនទូទៅដែលមានសក្តានុពលច្រើន ។ ការប្រឈមមុខគឺជាការបែងចែកនូវកម្មវិធីដែលមាន ដំណើរការពិតប្រាកដនៅក្នុងការអនុវត្តន៍ ហើយអាចធ្វើឱ្យមានចីរភាពដោយខ្លួនឯងដោយមិនចាំបាច់មានជំនួយ និងគាំទ្រ ខាងក្រៅដោយភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ RUPES គឺជាកម្មវិធីស្រាវជ្រាវរយៈពេលវែងសំរាប់ ក្នុងការអភិវឌ្ឍន៍ នៃការអនុវត្តន៍កម្មវិធីសេវាកម្មបរិស្ថាន ដែលអាចបញ្ចូលទៅក្នុងការងារក្នុងប្រទេសផ្សេងដោយកម្មវិធី ផ្សេងៗគ្នា ។

រយៈពេលជាង ៥ឆ្នាំ ពីឆ្នាំ ២០០២-០៧ កម្មវិធីដំណាក់ការដំបូងរបស់ RUPES 1 បានកសាងនូវគំរូការងារនៃ ការអនុវត្តន៍ ដ៏ប្រសើរ មួយនៅក្នុងកន្លែងស្រាវជ្រាវចំនួន ៦ នៅប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងនេប៉ាល និងលើសពីនេះបានសិក្សាពី បទពិសោធន៍ផ្សេងទៀតចំនួន ១២ ទូទាំងទ្វីបអាស៊ី ។

RUPES 1 បានទទួលជោគជ័យគួរឱ្យកត់សំគាល់ជាមួយ នឹងកម្មវិធីផ្តល់ការតបស្នងសំរាប់អ្នកថែរក្សាតំបន់ជម្រៀលដោយ ភ្ជាប់ទៅនឹងសេវាកម្មបរិស្ថាន ( ឧទាហរណ៍ : គុណភាពទឹក និងបរិមាណ) សំរាប់ស្ថានីយ៍វារីអគ្គីសនី និងបណ្តាប្រជាជននៅ ទីក្រុងតំបន់ខាងក្រោម ។ ចំនុចមួយក្នុងចំណោមចំនុចគន្លឹះជាច្រើន **គឺការឱ្យនិយមន័យឱ្យបានច្បាស់លាស់នៅលើសេវាកម្ម បរិស្ថាន ថាតើវាមានប្រភពមកពីណា ហើយមកយ៉ាងដូចម្តេច និងប្រយោជន៍ទៅទីណា និងយ៉ាងដូចម្តេច?.**

ក៏ដូចជា RUPES 1 ដែលរកឃើញ និងចាប់ផ្តើមជួបឧបសគ្គក្នុងការបង្កើតកម្មវិធីឡើងដូចជា

- កង្វះឆន្ទៈនយោបាយ សកម្មភាពជាប្រព័ន្ធ និងឯកសារគាំទ្រស្របច្បាប់
- ប្រភពធនធានហិរញ្ញវត្ថុមានកំរិត
- ចំណាប់អារម្មណ៍ និងការខិតខំប្រឹងប្រែង របស់សហគមន៍មានកំរិត

ការបង្កើតនូវស្ថាប័នបណ្តាញជាតិឯករាជ្យមួយ នៅក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ជាមួយនិងសមាជិកដែលមកពី ប្រភពផ្សេងៗគ្នា បានត្រួសត្រាយផ្លូវទៅលើឧបសគ្គទាំងនោះ។

លក្ខណៈវិនិច្ឆ័យ និងអាំងឌីកាទ័ ១ ដែលបានអភិវឌ្ឍន៍ដើម្បីស្វែងរកអត្តសញ្ញាណឱ្យកាន់តែប្រសើរឡើងនូវ "ឥទ្ធិភាព. លក្ខខ័ណ្ឌ ការស្ម័គ្រចិត្ត និងគាំទ្រអ្នកក្រីក្រ" គឺជាការតបស្នងទាក់ទងទៅនឹងអ្នកលក់គោលដៅ។

## RUPES II

កម្មវិធីនេះបច្ចុប្បន្ន គឺស្ថិតនៅដំណាក់កាលទី២។ វានឹងកសាងដោយផ្អែកទៅលើជោគជ័យ និងមេរៀនជាបទ ពិសោធន៍ដែលបានមកពី RUPES I ដែលរួបរួមនូវអ្វីដែលធ្វើទៅបាន និងធ្វើឱ្យទៅដល់ដៃគូរបន្ថែមទៀតសំរាប់ការរីក សាយភាយជាសកលនៃការទទួលយកនូវផលតបស្នងសំរាប់កម្មវិធីបរិស្ថាន។ ក្រុមគោលដៅសំរាប់ការស្រាវជ្រាវ គឺក្រុម ជនជាតិភាគតិចដែលរស់នៅក្នុងព្រៃ និងកសិករតូចតាចដែលរស់នៅក្នុងបរិស្ថានដែលផ្តល់ផលតិចតួច ដែលពួកគេជាអ្នករង គ្រោះពីការបង្ខូចបរិស្ថាន និងបំរែបំរួលអាកាសធាតុ។ ក្នុងចំណោមសកម្មភាពទាំងនោះរួមមាន

- **គោលនយោបាយ** : មានគោលបំណងធ្វើឱ្យមានផលប៉ះពាល់ជាសំខាន់ទៅលើគោលនយោបាយជាតិរបស់ដៃគូរ ដែលមាន នៅប្រទេសចិន ឥណ្ឌូនេស៊ី ឥណ្ឌា ហ្វីលីពីន នេប៉ាល់ និងវៀតណាម និងដៃគូរអន្តរជាតិផ្សេងទៀត តាមរយៈការធ្វើ សមាហរណកម្មកម្មវិធីសេវាកម្មបរិស្ថានទៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការអភិរក្សជាអទិភាព។

- **រដ្ឋាភិបាល** : គាំទ្រនូវអ្នកដឹកនាំថ្នាក់ជាតិ ថ្នាក់ខេត្ត ដល់ថ្នាក់តំបន់ ក្នុងការអភិវឌ្ឍន៍នូវការតបស្នងទៅលើសេវាកម្ម បរិស្ថាន។ មួយផ្នែក គឺត្រួតពិនិត្យលើជម្លោះដែលកើតឡើងញឹកញាប់ក្នុងប្រព័ន្ធតុលាការ ដែលជាឧបសគ្គជាស្ថាប័ន។

- **ការវិនិយោគ** : សាកល្បងការរៀបចំផែនការបង្កើតថ្មីសំរាប់ការវិនិយោគជាលក្ខណៈអន្តរជាតិ លើកម្មវិធីការ បន្ថយសារធាតុកាបូនដោយលើកទឹកចិត្តឱ្យមានការធ្វើជាដៃគូរជាមួយគ្នានៅតំបន់ព្រៃភ្នំ។



- **អ្នកទិញ និងអ្នកលក់** : ជំរុញឱ្យមានឱកាសសំរាប់អ្នកទិញចូលរួមក្នុងកម្មវិធីផ្តល់ការតបស្នង ខណៈពេលដែលពួកគេបាន ផ្តល់ជំនួយបច្ចេកទេសទៅដល់អ្នកលក់ ដើម្បីអភិវឌ្ឍន៍មុខរបស់របស់ពួកគេ។

- **ការអនុវត្តន៍ដោយប្រសើរ** : កត់ត្រានូវករណីដែលអនុវត្តន៍បានល្អក្នុងការចចារដើម្បីគាំទ្រនូវការលេចឡើងនូវបញ្ញាតិ និង មាត្រដ្ឋានជាសកលសំរាប់កម្មវិធីសេវាកម្មបរិស្ថាន។ ដំណាក់កាលទី ១ ទីកន្លែងធ្វើស្រាវជ្រាវ និងក្លាយជាមជ្ឈមណ្ឌល សំរាប់សិក្សាដើម្បីជូញដល់អ្នកទិញ អ្នកលក់ និងឈ្មួញកណ្តាល និងផ្សព្វផ្សាយបន្តនូវការអនុវត្តន៍ជាគំរូនៅទូទាំងអាស៊ី និង ធ្វើឱ្យប្រាកដនូវចេរភាពនៃកម្មវិធីដែលមានស្រាប់។

- **ការតបស្នងថ្មី** : សាកល្បងជំរើសថ្មី ដើម្បីបន្តនូវការកំណត់ព្រំដែនយន្តការ នៃការតបស្នងជាហិរញ្ញវត្ថុ និងមិនមែន ជាហិរញ្ញវត្ថុ ក្នុងកិរិតសហគមន៍ និងគ្រួសារ។ នៅក្នុងប្រភេទថ្មីនៃការផ្តល់ផលតបស្នង និងយន្តការរបស់ពួកគេ គឺជាកម្មវិធី bio-rights. គំរោង Micro-hydro និងការបញ្ចូលទៅក្នុងទីផ្សារ សំរាប់ផលិតផលធ្លាជាតិគីមី។

- **ការអនុវត្តន៍នៃសេវាកម្មបរិស្ថានថ្មី** : ស្ថាបនាផលប្រយោជន៍ប្រជាជននៅជនបទពីការការពារទីជម្រាល និងការចំណាយលើសារធាតុកាបូនជាសកល គួរតែធ្វើទៅបានបន្ទាប់ពីកិច្ចប្រជុំរបស់ UNFCCC COP13 នៅបាលី ក្នុងខែធ្នូ ឆ្នាំ ២០០៧ ដោយតាំងចិត្តដោយធ្វើសកម្មភាពបង្ហាញពីតំរូវការទៅលើ " ការកាត់បន្ថយការសឹករិចរិលដោយការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រភេទកំពុងអភិវឌ្ឍន៍ ។ ហើយក៏ស្វែងរកឱកាសដើម្បីសំរបសំរួល និងជំរុញឱ្យមានទីផ្សារសំរាប់ដំណាំ អនុផលព្រៃឈើនៅតំបន់កសិ-រុក្ខកម្ម និងតំបន់ដែលសំបូរដោយជីវៈចំរុះ ។

ផែនទីនៃតំបន់សិក្សា ធ្វើស្រាវជ្រាវ របស់ RUPES



# កម្ពុជា-របកគំហើញថ្មីនៃការផល់ការតបស្នងក្នុងកម្មវិធីសេវាកម្មបរិស្ថានសំរាប់អ្នកក្រីក្រ

តំបន់អភិរក្សរមានទីតាំងនៅខេតបន្ទាយមានជ័យប៉ែកខាងលិចឈៀងខាងជើងប្រទេសកម្ពុជា ។ វាជាតំបន់ឆ្លងកាត់ដ៏សំខាន់
ពីតំបន់ព្រំដែនទៅខេត្តសៀមរាបអង្គរប្រទេសកម្ពុជា ។

ខេត្តបន្ទាយមានជ័យ គឺជាតំបន់ដ៏សំខាន់មួយសំរាប់វិស័យកសិកម្ម ជាពិសេសដំណាំស្រូវ ។ ស្ទឹងសិរីសោភ័ណដែលមានប្រភព ទឹកពីផ្ទៃដី ៤៣៤៣ គ.ម
ការេ គឺជាប្រភពទឹកដ៏សំខាន់សំរាប់កសិកម្មនៅជុំវិញខេត្ត និងតំបន់ជុំវិញនោះ ។ ស្ទឹងសិរីសោភ័ណ ( មើលរូបភាព១)
គឺប្រភពទឹកដ៏សំខាន់មួយរបស់ទន្លេសាបផងដែរ ( ដែលជាបឹងធំបំផុតនៅតំបន់អាស៊ីអាគ្នេយ៍ និងដែល កំណត់ដោយ UNESCO ថាជាតំបន់ជីវៈចំរុះ
និងប្រព័ន្ធអេកូឡូស៊ី) ។ វាទទួលទឹកភ្លៀងប្រហែល ១៥០០ មីលីម៉ែត្រ ក្នុងមួយឆ្នាំហើយប្រហែល ៦៥៩០ ម៉ែត្រគូប ។

នៅ ៣០ឆ្នាំចុងក្រោយ តំបន់នេះជាតំបន់កសិកម្មដដែល តែទោះបីយ៉ាងណាក៏ដោយមានតំបន់មួយចំនួនមិនអាចប្រើ
ប្រាស់បានដោយសារមិនមានគ្រាប់មីន ។ ទន្ទឹមនឹងភាគច្រើនប្រជាជននៅតំបន់នោះជាកសិករ និងអ្នកនេសាទខ្មែរ ហើយ
ក៏មានប្រជាជនភាគតិចជាជនជាតិលាវផងដែរ ។



សាកលវិទ្យាល័យមានជ័យជា សាលកវិទ្យាល័យមួយដែលទើបនឹងកសាងនៅឆ្នាំ ២០០៧ ដែលមានទីតាំងនៅតាមបណ្តោយ ស្ទឹងសិរីសោភ័ណ បានផ្តួចផ្តើមតំបន់អភិរក្ស ដែលធ្វើការការពារតំបន់ពូជត្រីធម្មជាតិ មានប្រវែង ២០០ ម៉ែត្រការេ ។ នៅក្នុង ឆ្នាំ ២០០៩ គណៈអភិបាលខេត្តបន្ទាយមានជ័យ ឯកឧត្តម អ៊ុង អឿន ឯកឧត្តម តូច ជឿន សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យមានជ័យ និងរដ្ឋបាលខ័ណ្ឌជលផល ខេត្តបន្ទាយមានជ័យបានទទួលស្គាល់ជាផ្លូវការនូវតំបន់ស្ទឹងខាងក្រោយសាកលវិទ្យាល័យមានជ័យជាតំបន់អភិរក្សពូជត្រីធម្មជាតិ ។ គោលបំណងនៃការខិតខំប្រឹងប្រែង គឺដើម្បីបង្កើតទិន្នផលត្រីសំរាប់ប្រជាពលរដ្ឋនៅជុំវិញតំបន់នោះ និងបឹងទន្លេសាប ។ ទន្ទឹមនឹងនោះដែរ សាកលវិទ្យាល័យមានជ័យក៏កំពុងតែត្រូវការជំនួយបច្ចេកទេសដើម្បីការពារការគំរាមកំហែងចំពោះតំបន់អភិរក្សពូជត្រីនេះ ទន្ទឹមនឹងនោះប្រជាជននៅតំបន់ខាងលើប្រើប្រាស់យ៉ាងសកម្មនូវថ្នាំពុល និងជីគីមី ។ ដោយឡែកការបង្កើតតំបន់អភិរក្សពូជត្រីនេះក៏មានគោលបំណងអភិរក្សឱ្យក្លាយជាតំបន់ទេសចរណ៍ធម្មជាតិផងដែរ ។

## តំបន់សក្តានុពលផ្សេងទៀតសំរាប់កម្មវិធី PES ថ្មី

ទេសចរណ៍ធម្មជាតិ ៖ ប្រទេសកម្ពុជាគ្រប់ដណ្តប់ដោយផ្ទៃដី និងផ្ទៃទឹកដែលមានវិសាលភាពយ៉ាងធំធេង ទន្ទឹមនឹងនោះក៏មានវិសាលភាពផ្នែកសំណង់ប្រាសាទបែបព្រះពុទ្ធសាសនាផងដែរ ។ បណ្តាញសហគមន៍ទេសចរណ៍កម្ពុជា (CCBEN) គឺជាបណ្តាញសហគមន៍នៅជនបទ អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងក្រុមហ៊ុនឯកជន ដែលកំពុងធ្វើការទៅលើទេសចរណ៍ធម្មជាតិ ។ វាមានគោលបំណងដើម្បីគាំទ្រជំរុញ និងស្វែងរកការគាំទ្រសំរាប់វិស័យទេសចរណ៍ដែលមានលក្ខណៈតែមួយនេះដើម្បីការពារធនធានធម្មជាតិ និងវប្បធម៌ បរិស្ថាន និងការរស់នៅដោយចីរភាពរបស់សហគមន៍ នៅ ជនបទទូទាំងប្រទេស ។ គេហទំព័រ: www.ccben.org

**ការគ្រប់គ្រងដីធ្លីដោយចីរភាព** (SLM) កម្មវិធីជាតិរបស់កម្ពុជា និងស្វែងរកការអនុវត្តន៍យ៉ាងល្អសំរាប់ការធ្វើកសិកម្មដែលនឹងធ្វើឱ្យប្រសើរឡើងនូវសេវាកម្មបរិស្ថាននៅលើផ្ទៃដីកសិកម្ម ។ គំរោងរបស់ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ (MAFF) UNDP និង GEF នឹងនូវការកសាងសមត្ថភាព និងបញ្ច្រៀបទៅដល់ថ្នាក់មូលដ្ឋានតាមរយៈ:



- បង្កើតចំនេះដឹង និងជំនាញក្នុងការអនុវត្តន៍ទៅលើការគ្រប់គ្រងដីធ្លី ក្នុងចំណោមសហគមន៍នៅជនបទ និងភ្នាក់ងារ គាំទ្របច្ចេកទេសរដ្ឋបាលមូលដ្ឋាន ។
- ពង្រឹងគោលនយោបាយ និងពង្រីកការចែករំលែកចំនេះដឹងក្នុងចំណោមអ្នកពាក់ព័ន្ធ និង
- ធ្វើការតស៊ូមតិដោយប្រសិទ្ធភាពនូវធនធានថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដើម្បីគាំទ្រការគ្រប់គ្រងដីធ្លីដោយចីរភាព



